**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧០.សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការទទួលស្គាល់ជាផ្លូវការនូវការកែសម្រួលសមាសភាពក្រុមការងារផ្នែកស្រូវ-អង្ករ ផ្នែកឯកជននៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យឯកជន
- បានឃើញសេចក្តីសម្រេចលេខ ៣៦ សសរ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតអនុគណៈកម្មាធិការតាមវិស័យនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យឯកជន
- បានឃើញសេចក្តីសម្រេចលេខ ៣៧ សសរ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាជាមួយវិស័យឯកជន
- បានឃើញសេចក្តីសម្រេចលេខ ៣៨ សសរ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យឯកជន
- បានឃើញសេចក្តីសម្រេចលេខ ០០១ សសរ/សហវ/គសហ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពអនុគណៈកម្មាធិការតាមវិស័យនៃគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យឯកជន
- បានឃើញសេចក្តីសម្រេចលេខ ៣៩ សសរ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពក្រុមការងារតាមវិស័យសម្រាប់ធ្វើជាដៃគូពិភាក្សាជាមួយវិស័យឯកជន
- យោងលិខិតលេខ ០០៥/១៤ សភពណ.កជ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ របស់សភាពាណិជ្ជកម្មកម្ពុជា

www.pheakdeylaw.com

- បានឃើញសេចក្តីសម្រេចលេខ ៤៧ សសរ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការទទួលស្គាល់ជាផ្លូវការនូវសមាសភាពក្រុមការងារទាំង១០ ផ្នែកឯកជននៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន
- យោងលិខិតលេខ ០០៩/១៦ សកពណ.កជ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ របស់សភាពាណិជ្ជកម្មកម្ពុជា
- យោងមតិរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ អនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

ប្រការ១.- កែសម្រួលខ្លឹមសារប្រការ១ នៃសេចក្តីសម្រេចលេខ ៤៧ សសរ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការទទួលស្គាល់ជាផ្លូវការនូវសមាសភាពក្រុមការងារទាំង១០ ផ្នែកឯកជននៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ត្រង់ផ្នែក ឈ ក្រុមការងារផ្នែកស្រូវ-អង្ករ ដូចខាងក្រោម ៖

| | |
|---|---|
| ១- ឯកឧត្តម សុខ ពុទ្ធិវុធ | សហប្រធាន |
| ២- ឧកញ៉ា គឹម សាវុធ | អនុប្រធាន |
| ៣- ឧកញ៉ា ហ៊ុន ឡាក់ | សមាជិក |
| ៤- ឧកញ៉ា ភូ ពុយ | សមាជិក |
| ៥- ឯកឧត្តម សុខ ហាច | សមាជិក |
| ៦- ឧកញ៉ា សុង សារ៉ន | សមាជិក |
| ៧- ឧកញ៉ា ចាន់ សុឃាំង | សមាជិក |
| ៨- លោក នង វាសនា | សមាជិក |
| ៩- លោក តាំង ឆុងអ៊ី | សមាជិក |

ប្រការ២.- ក្រៅពីការកែសម្រួលដូចមានចែងក្នុងប្រការ១ខាងលើ ខ្លឹមសារប្រការផ្សេងៗទៀតនៃសេចក្តីសម្រេចលេខ ៤៧ សសរ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការទទួលស្គាល់ជាផ្លូវការនូវសមាសភាពក្រុមការងារទាំង ១០ ផ្នែកឯកជននៃវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន នៅរក្សាដដែល។

ប្រការ៣.- អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ សភាពាណិជ្ជកម្មកម្ពុជា និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ដូចប្រការ ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



www.pheakdeylaw.com